# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0137**

## សម្ភាសន៍ជាមួយឈ្មោះ ហួន ចាន់រីន ភេទស្រី អាយុ៥៣ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ “ប្រជាជនធ្វើការកងចល័ត”
## សព្វថ្ងៃរស់នៅភូមិជ្រោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## សម្ភាសន៍ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៥:២០

**២៨ទំព័រ**

វណ្ណៈ៖ អញ្ចឹងថ្ងៃនេះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ហើយខ្ញុំឈ្មោះសុខ វណ្ណៈ ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកដល់ភូមិឃុំមីងគឺចង់ដឹងរឿងរ៉ាវដែលទាក់ទងនៅក្នុងសម័យខ្មែរក្រហម ផ្ដោតពីឆ្នាំ៧៥ដល់ឆ្នាំ៧៩ អីចឹងនៅក្នុងអំឡុងពេលហ្នឹង តើប្រជាជនជួបការលំបាកយ៉ាងម៉េចខ្លះ ហើយដូចថានៅក្នុងភូមិយើងក្រោយមក៧៩ទៀត តើយើងធ្វើអីបន្តរបង្កើនផលយ៉ាងម៉េច ហើយប្រជាជនមានជីវភាពយ៉ាងម៉េច? អាហ្នឹងខ្ញុំចង់ដឹងរឿងរ៉ាវហ្នឹងបន្តទៀតណាមីងណា៎? ហើយចាំមីងនិយាយៗបន្តិច អញ្ចឹងបទសម្ភាសន៍ខ្ញុំជាមួយមីងហ្នឹងតើមីងអនុញ្ញាតិឲ្យខាងខ្ញុំហ្នឹងយកទៅប្រើការដូចជា សរសេរជាសៀវភៅទស្សនាវដ្ដីឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮ បានទេមីង?

រីនៈ ចា៎!

វណ្ណៈ៖ អត់អីទេមីង?

រីនៈ ចា៎!

វណ្ណៈ៖ អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីដែរ?

រីនៈ ឈ្មោះ ហួន ចាន់រីន ។

វណ្ណៈ៖ អត់មានឈ្មោះក្រៅទៀតទេមីង?

រីនៈ អត់ទេ ប្រើតែឈ្មោះមួយនេះ ។

វណ្ណៈ៖ ចុះមីងអាយុប៉ុន្មានហើយ?

រីនៈ អាយុ៥៣ ។

វណ្ណៈ៖ ប្ដីមីងឈ្មោះអីដែរ?

រីនៈ ឈ្មោះ ធឹម សឹត ។

វណ្ណៈ	គាត់អាយុប៉ុន្មានដែរ?

រីនៈ	អាយុ៦០ឆ្នាំ ។

វណ្ណៈ	សព្វថ្ងៃមានកូនប៉ុន្មាននាក់ដែរ?

រីនៈ	មានកូន៥នាក់ ។

វណ្ណៈ	៥នាក់ហ្នឹងស្រីប៉ុន្មានដែរ?

រីនៈ	ស្រី៣នាក់ ប្រុស២នាក់ ។

វណ្ណៈ	ឪពុកមីងឈ្មោះអីដែរ?

រីនៈ	ឈ្មោះ ហួន សារឿង ។

វណ្ណៈ	ចុះម្តាយ?

រីនៈ	សង ណយ ។

វណ្ណៈ	គាត់ទាំងពីរស្លាប់ឬក៏នៅរស់?

រីនៈ	នៅរស់មួយ ទើបតែស្លាប់មួយ ។

វណ្ណៈ	រស់ម្តាយ?

រីនៈ	ចា៎!

វណ្ណៈ	បងប្អូនរបស់មីងទាំងអស់មានប៉ុន្មាននាក់?

រីនៈ	ងាប់អស់២នាក់ហើយ នៅសល់តែនាក់ទេ ទាំងអស់៥នាក់ ។

វណ្ណៈ	នៅសល់ប៉ុន្មាន?

រីនៈ	សល់៣នាក់ ។

វណ្ណៈ	ហើយ២នាក់ទៀតស្លាប់ក្រោយ៧៩ ឬក៏ស្លាប់ជំនាន់ខ្មែរក្រហម?

រីនៈ	ក្រោយ៧៩ គេចូលបួន់ គេបួន់យកម៉ូតូ ។

វណ្ណៈ	អីចឹងមីង ស្រុកកំណើតរបស់មីងហ្នងនៅភូមិអី?

រីនៈ	នៅភូមិប៉ោយក្បឿង ដល់ពេលគេជម្លៀសចេញទៅចូលនៅប៉ោយក្បឿងវិញដដែល គេដកខ្ញុំដាក់ក្រុមចំរុះ ។

វណ្ណៈ	ឃុំហ្នឹងគេហៅឃុំព្រះនេត្រព្រះហ្នង?

រីនៈ	ចា៎! ឃុំព្រះនេត្រព្រះ ។

វណ្ណៈ	ស្រុក?

រីនៈ	ស្រុកព្រះនេត្រព្រះដែរ ។

វណ្ណៈ ពីដើមខេត្តបាត់ដំបង?

រីនៈ ចា៎!

វណ្ណៈ ចុះឥឡូវនៅភូមិហ្នឹងដដែល?

រីនៈ ចា៎! នៅភូមិហ្នឹងដដែល ។

វណ្ណៈ តែខេត្តបន្ទាយមានជ័យវិញ?

រីនៈ ចា៎!

វណ្ណៈ ភូមិឃុំនៅដដែលទេ?

រីនៈ ចា៎! នៅដដែល ។

វណ្ណៈ អញ្ចឹងមីង ខ្ញុំចង់ឲ្យមីងនិយាយកាលពីមីងនៅពីតូច បានរៀនសូត្រទេ?

រីនៈ រៀនបាន៣ថ្នាក់ដែរ ។

វណ្ណៈ អញ្ចឹងមីងរៀនបានថ្នាក់ទី១០ចាស់?

រីនៈ រៀនទី៩បានកន្លះខែ ត្រៀមវ៉ាកង់តូចគេឈប់ ។

វណ្ណៈ រៀននៅសាលាណា?

រីនៈ រៀននៅសាលាព្រះនេត្រព្រះ ឃុំព្រះនេត្រព្រះ ។

វណ្ណៈ សាលាបឋមព្រះនេត្រព្រះ?

រីនៈ ចា៎!

វណ្ណៈ យ៉ាងម៉េចបានមីងឈប់រៀនត្រឹមថ្នាក់ទី១០ ទី៩បានពាក់កណ្ដាលអីចឹង?

រីនៈ កាលហ្នឹងគេកំពុងផ្ទើល ស្រុកសង្គ្រាម ។

វណ្ណៈ ស្រុកមានសង្គ្រាម?

រីនៈ ចា៎! គេផ្ទើល រត់ត្រដេកត្រដុបទៅព្រៃ ។

វណ្ណៈ ស្រុកសង្គ្រាមហ្នឹងសង្គ្រាមយ៉ាងម៉េច មីងជួយរៀបបន្តិចបានទេ ដូចថាវាមានហេតុការណ៍អីកើតឡើងនៅក្នុងសម័យហ្នឹង?

រីនៈ សង្គ្រាមកាលនោះបាញ់គ្នា កាលហ្នឹងប៉ុល ពត បាញ់លន់ ធល់ ហើយមានទម្លាក់គ្រាប់បែកទម្លាក់អី ផ្ទើលខ្លាចទៅមិនហ៊ានទៅរៀនទៅ ។

វណ្ណៈ អីចឹងនៅក្នុងភូមិហ្នឹងមានឆេះមានអីទេ?

រីនៈ ឆេះតែបៀតក្នុងភូមិនេះ ឆេះតែឃុំ ភូមិនេះមានតគ្នាក៏ស្លាប់ទៅ ហើយស្លាប់យាយខ្ញុំអស់ម្នាក់ ដែលបាញ់តគ្នា ។

វណ្ណៈ អាហ្នឹងស្លាប់ដោយសារបាញ់ មិនមែនស្លាប់ដោយសារទម្លាក់គ្រាប់បែកទេ?

វីនៈ ទេបាញ់ វាចូលមកវ៉ៃទៅហើយវាបាញ់សម្លាប់ហ្នឹង ហើយខ្ញុំនៅតូចនៅជាមួយយាយ ដល់ពេលនៅតូចអីចឹងមានអ្នកណានឹងចាប់ផ្តើម ខ្ញុំនៅអាយុប៉ុន្មានហ្នឹងកាលហ្នឹង នៅអាយុប្រហែល១៣-១៤ហ្នឹង ។

វណ្ណៈ អីចឹងរយៈពេលហ្នឹងមីងឈប់រៀនដោយសារសង្គ្រាមរត់លូនអញ្ចឹងទៅ?

វីនៈ ចា៎! ដល់ពេលយាយស្លាប់អញ្ចឹងទៅ ខ្ញុំក៏ខានរៀន ហើយម្តាយនៅបាត់ដំបង ហើយខ្ញុំនៅជាមួយយាយឯនេះ ដល់ពេលម៉ែឪបកពីបាត់ដំបងមកវិញបានតែ២ថ្ងៃ គេបិទផ្លូវឡានហ្នឹងកុំអីបែកគ្នា ។

វណ្ណៈ អីចឹងនៅហ្នឹង មីងមានដឹងពេលរដ្ឋប្រហារទម្លាក់សម្តេចសីហនុហើយ តើខាងខ្មែរក្រហមមានចូលមកលុកលុយក្នុងភូមិហ្នឹងទេ ខាងចលនាអីគេមានមកឃោសនាទេ?

វីនៈ ទេ អត់ទាន់មានចូលទេ ស្រាប់តែវាចូលមកវ៉ៃហ្នឹង ។

វណ្ណៈ អីចឹងពេលមីងឈប់រៀន មានទាហានលន់ ណុល នៅចូលក្នុងភូមិហ្នឹងនៅឡើយ ឬក៏ថយចេញទៅក្រៅ?

វីនៈ ទាហាននៅក្នុងនេះ នៅពេញនេះឯង ។

វណ្ណៈ ចុះ៧១-៧២-៧៣អី ទាហានលន់ នល់ យ៉ាងម៉េចដែរ?

វីនៈ កាលហ្នឹងអត់ទាន់វ៉ៃបានទេ វាវ៉ៃបានតែរៀបចប់ វាអត់មានឈរជើងទេ វ៉ៃរួចវាដកចេញ ។

វណ្ណៈ វ៉ៃជាមួយទាហានខ្មែរក្រហមហ្នឹង?

វីនៈ ចា៎! លន់ ណុល វ៉ៃជាមួយខ្មែរក្រហម ។

វណ្ណៈ អីចឹងបងប្អូនមីងអី មានដែលបានចូលបម្រើទៅខាងខ្មែរក្រហមទេ ខាងចលនា?

វីនៈ អត់ទេ កាលហ្នឹងនៅតូចៗ ។

វណ្ណៈ ចុះនៅខាងលន់ ណុល មានទេ?

វីនៈ អត់មានទេ ។

វណ្ណៈ ចុះមីងកូនទីប៉ុន្មាន?

វីនៈ កូនទី១ ។

វណ្ណៈ បងគេ?

វីនៈ ចា៎! បងគេ ហើយអាប្អូនៗនោះនៅតូចៗ ហើយខ្ញុំនៅស្មើរជាងនេះទៀតហ្នឹង មានទាន់ធំណា៎ ។

វណ្ណៈ អីចឹងគ្រាប់បែកអត់មានទម្លាក់នៅក្នុងភូមិនេះទេ គឺតាមជាយៗទេ?

រីនៈ ទម្លាក់នៅស្រែះ។

វណ្ណៈ ទម្លាក់តាមស្រែះ?

រីនៈ ចា៎! តាមស្រែះហ្នឹងទម្លាក់២គ្រាប់។

វណ្ណៈ អ៎! គេហៅភូមិស្រែះ?

រីនៈ ចា៎! ទម្លាក់នៅហ្នឹង នៅភូមិស្រែះ។

វណ្ណៈ ហើយមានស្លាប់មនុស្សទេ?

រីនៈ កាលនោះខ្ញុំនៅតូច កាលហ្នឹងឆេះអស់ផ្ទះមួយ។

វណ្ណៈ អីចឹងដល់ពេលចូលដល់ខ្មែរក្រហមកាន់កាប់នៅហ្នឹង មីងមានដឹងទេ កាន់កាប់ដូចថាឆ្នាំណាខ្មែរក្រហមកាន់កាប់ក្នុងភូមិ?

រីនៈ វាគ្រាន់តែចូលវៃរួចក៏វាចេញទៅវិញ ដល់ចូលមកចុងក្រោយឆ្នាំប៉ុន្មានទេ ខ្ញុំមិនសូវដឹងដែរ កាលហ្នឹង ដូចជា៧៥ ចប់ហើយវាចូលមកកាន់ហ្មង។

វណ្ណៈ អីចឹង៧៥ ពេលឆ្នាំ៧៥ពេលខ្មែរក្រហមចូលមកដល់ដំបូង តើប្រាប់ប្រជាជនឲ្យធ្វើអីខ្លះ?

រីនៈ ពេលដែលវាចូលមកដល់ដំបូង វាដេញជម្លៀសយើងចេញហ្មង ជម្លៀសទៅនៅភ្នំកូនដំរី វាជម្លៀសទៅហ្នឹង។

វណ្ណៈ អីចឹងកាល៧៥ហ្នឹងវាជម្លៀសទៅភ្នំកូនដំរី?

រីនៈ ចា៎! បកពីកូនដំរីទៅនៅស្រែះទៀត។

វណ្ណៈ ទៅស្រែះទៀត?

រីនៈ ចា៎!

វណ្ណៈ ទៅភ្នំកូនដំរីបានរយៈពេលប៉ុន្មាន បានទៅស្រែះទៀត?

រីនៈ ប្រហែលជា៧ថ្ងៃ ៧ថ្ងៃវាឲ្យឡើងមក ឡើងបាន៣ថ្ងៃរួចបានវាជម្លៀសទៅស្រែះទៀត។

វណ្ណៈ តែ៣ថ្ងៃទេ?

រីនៈ ចា៎!

វណ្ណៈ ហើយបានទៅស្រែះ?

រីនៈ អាស៎! ពេលទៅនោះ៧ថ្ងៃ ដល់ពេលបាន៧ថ្ងៃបានបកជម្លៀសទៅស្រែះ បានមកនៅភូមិហ្នឹង៣ថ្ងៃ បាន៣ថ្ងៃហើយបានវាជម្លៀសទៅស្រែះទៀត។

វណ្ណៈ ទៅស្រែះហ្នឹងរហូតដល់ពេលណា?

រីនៈ ទៅស្រែះហ្នឹងគ្រាន់ដែរហ្នឹង ។

វណ្ណៈ បានមួយឆ្នាំទេ?

រីនៈ ចា៎! ប្រហែលជាមួយឆ្នាំដែរហ្នឹង យើងទៅខែចេត្រ ព្រោះរួចអញ្ចឹងខែនេះបានឡើងមកវិញ មិនដល់មួយឆ្នាំទេ ប្រហែលជា៧ខែ ។

វណ្ណៈ ៧ខែហើយ ត្រលប់មកចូលក្នុងភូមិប៉ោយក្បៀងនេះវិញ?

រីនៈ ចា៎!

វណ្ណៈ ដល់ភូមិប៉ោយក្បៀងហ្នឹងវិញ តើនៅក្នុងភូមិហ្នឹងដូចថា ថ្នាក់ដឹកនាំដំបូងអ្នកស្រុកអ្នកភូមិយើង ដែរឬអ្នកមកពីចម្ងាយ?

រីនៈ អ្នកភូមិផងអ្នកមកពីចម្ងាយផង ។

វណ្ណៈ អ្នកមកពីចម្ងាយតាមដឹងប្រហែលជាចុងក្រោយមកទៀតទេ ជិតបែក៧៩បានមានអ្នកថ្មី?

រីនៈ ចា៎! មុនដំបូងអ្នកភូមិនេះឯងក្តាប់ ។

វណ្ណៈ ពីណាគេ?

រីនៈ តាហឿន ។

វណ្ណៈ តាហឿន ពីឆ្នាំណាដល់ឆ្នាំណា ពី៧៥ដល់ឆ្នាំណា?

រីនៈ កាលហ្នឹងខ្ញុំគេបញ្ជូនទៅចល័តបាត់ហើយ ។

វណ្ណៈ អ៊ីចឹងមីងអត់ដឹងទេ?

រីនៈ ចា៎! អត់ដឹងទេ ដឹងតែតាហឿន ។

វណ្ណៈ ក្រោយមក តាហឿន គេចាប់ខ្លួនគាត់ឬក៏គាត់នៅរស់ដល់សព្វថ្ងៃហ្នឹងដែរ?

រីនៈ គាត់នៅរស់ គេទម្លាក់គាត់ចេញពីខាងសៀមរាបមកក្តោបក្តាប់ម្តង ដល់សៀមរាបរួចបាន ខាងនិរតីគេក្តាប់បណ្តើរៗគ្នា ខាងសៀមរាបគេសម្លាប់ចោលម្តង រួចបានខាងនិរតី ខាង និរតីរួចបានសៀមរាបទៀត វាច្របូកច្របល់គ្នាណា៎ ដូចថាមកម្តងគេសម្លាប់ម្តង ហើយមក ម្តងក្តាប់ទៀត ។

វណ្ណៈ អ៊ីចឹងនៅនេះសម្លាប់ក៏សម្លាប់ ហើយអត់បាយក៏អត់បាយ?

រីនៈ ចា៎!

វណ្ណៈ វេទនាដែរអ៊ីចឹង?

រីនៈ ចា៎! ក្នុងភូមិហ្នឹងវេទនា ។

វណ្ណៈ ចុះមីង ឆ្នាំណាមីងទៅកងចល័ត ឆ្នាំ៧៥ខ្មែរក្រហមចូលមកហ្នុង?

រីនៈ ចាំ! ឆ្នាំ៧៥ ខ្មែរក្រហមចូលមកខ្ញុំចេញចល័តរហូត ។

វណ្ណៈ ដល់បែកយួនចូលហ្នឹង?

រីនៈ ចាំ! ដល់យួនចូលតែម្តង ។

វណ្ណៈ ដូចថាពី៧៥ ទៅកងចល័តហ្នឹង កាលហ្នឹងពីណាមកហៅមីងឲ្យទៅកងចល័ត?

រីនៈ កាលនោះក្នុងភូមិនេះឯងគេចាត់ឲ្យទៅ ។

វណ្ណៈ ក្នុងភូមិ តាហឿន ហ្នឹងមែន?

រីនៈ ចាំ! តាហឿន ។

វណ្ណៈ ចុះចេញទៅកងចល័តហ្នឹង ដែលមកជួបម៉ែឪល្ងាចៗវិញទេ?

រីនៈ អត់ទេ គេបញ្ជូនទៅនោះអត់ដែលបានជួបទេ ខ្ញុំទៅនោះជិតមួយឆ្នាំ ដូចថាមកជួបអញ្ចឹងបាន នៅ៨-១០ថ្ងៃវារើសឲ្យទៅទៀត បញ្ជូនយើងទៅទៀត ។

វណ្ណៈ កងចល័តនៅម្តុំណា?

រីនៈ អាមុនដំបូងនៅគោករំចេកទី១ ។

វណ្ណៈ គោករំចេកហ្នឹងគេឲ្យធ្វើអីខ្លះ?

រីនៈ លើកទំនប់ គោករំចេកទី១ ទៅខាងថ្នលពួកទី២ ថ្នលពួកគេឲ្យច្រូតណាំ បកពីថ្នលពួកមកខ្ញុំនៅគេហៅ ស្ពីគេទេ គេហៅស្វាយ នៅកងវ៉ា ។

វណ្ណៈ អ៊ីចឹងឥឡូវខ្ញុំចង់ទៅគោករំចេកសិន គេឲ្យលើកទំនប់ហ្នឹងលើកយ៉ាងម៉េច?

រីនៈ បង្គីរកាន់អញ្ចឹងវាឲ្យយើងឈរតគ្នា គេអ្នកកាប់ហើយយើងអ្នកហុច ចាក់ហើយហុច គេឈរ តម្រៀបគ្នាអញ្ចឹង ។

វណ្ណៈ កាលជំនាន់ហ្នឹងគេអត់ទាន់វាស់ម៉ែត្រចែកទេ?

រីនៈ ចាំ! នៅលើកកម្ទាំង ឈរតម្រៀបយើងរុញគ្នាទៅ ហុចតគ្នា ។

វណ្ណៈ លើកបង្គីរតគ្នា?

រីនៈ ចាំ!

វណ្ណៈ អ៊ីចឹងកាលហ្នឹងមិនទាន់មានផែនការដាក់ម៉ែត្រគីបទេ?

រីនៈ អត់នៅ អត់មានទេ ។

វណ្ណៈ ចុះនៅលើកទំនប់ហ្នឹងពីណាគេគ្រប់គ្រង?

រីនៈ ខ្ញុំអត់ស្គាល់គេទេ ។

វណ្ណៈ អត់ស្គាល់ទេ?

រីនៈ ចាំ! អត់ស្គាល់ទេ សុទ្ធតែពួកយោធាទាំងអស់អ្នកដែលកាន់ក្តាប់ហ្នឹង ។

វណ្ណៈ យោធាកាន់កាប់កងចល័ត?

រីនៈ ចាំ! ហើយខ្ញុំអត់ស្គាល់ទេកាលហ្នឹង ។

វណ្ណៈ លើកទំនប់ ដែលមីងថាលើកទំនប់គន្លាហ្នឹង តើទំនប់ហ្នឹងគេលើកធ្វើអី?

រីនៈ គេលើកដើម្បីកាត់យកទឹកមិនដឹង មិនដឹងគេលើកយ៉ាងម៉េចដែង អាទំនប់ដើមគរ៣ដើមចុះទៅ វាលអញ្ចឹងណាំ ចុះទៅខាងត្បូងអីចឹងណាំ បៀតភ្នំស្រុកណាំ

វណ្ណៈ ទំនប់ទប់ទឹក?

រីនៈ ចាំ! ទប់ទឹក ។

វណ្ណៈ ទប់ទឹកយកធ្វើស្រែ?

រីនៈ ចាំ!

វណ្ណៈ ធ្វើហើយទេទំនប់ហ្នឹង?

រីនៈ ហើយ ធ្វើហើយ ។

វណ្ណៈ មានប្រវែងប្រហែលជាប៉ុន្មានម៉ែត្រ មីងអាចស្មានបានទេ?

រីនៈ ប្រហែលជា៨គីឡូ ។

វណ្ណៈ ៨គីឡូឆ្ងាយណាស់?

រីនៈ ឆ្ងាយ ។

វណ្ណៈ ហួសវត្តទៅទៀតអីចឹង?

រីនៈ ចាំ! ឆ្ងាយជាងវត្តទៀត កាលហ្នឹង៨មិនដឹង៩មិនដឹង កាលហ្នឹងពូគេនិយាយដែរ តែភ្លេចធ្លាក់ដល់មាត់ស៊ឹង ។

វណ្ណៈ អីចឹងប្រហែលជា៩គីឡូហើយ?

រីនៈ ចាំ! វាឆ្ងាយដែរ ឆ្ងាយសន្ធឹម ។

វណ្ណៈ អីចឹងដូចការលើកទំនប់ហ្នឹង តើមីងមានឃើញមនុស្សច្រើនទេ?

រីនៈ ច្រើន ។

វណ្ណៈ ប្រហែលជាប៉ុន្មានពាន់ប៉ុន្មានម៉ឺននាក់ទៅ?

រីនៈ ប្រហែលជាចូលម៉ឺន ព្រោះឃើញតម្រៀបគ្នាមើលទៅឃើញក្បាលឡើងកកគ្នា ម៉ាតំបន់៥គេប្រមូលចូលទាំងអស់មួយកន្លែងតែម្តង ។

វណ្ណៈ មានប្រុសមានស្រី?

រីនៈ ចា៎! ប្រុសស្រី ចាស់ក្មេង ។

វណ្ណៈ កាលលើកទំនប់៧៥ហ្នឹងមានពួកភ្នំពេញមកនូវ?

រីនៈ ទេ មិនទាន់មកទេ មានតែកម្លាំងយើងអ្នកស្រុកហ្នឹង ដល់ចប់ទំនប់ហ្នឹងបានអ្នកភ្នំពេញមកតាម ក្រោយ ។

វណ្ណៈ ចុះទំនប់ហ្នឹង កាលលើកទំនប់ហ្នឹងតើអ្នកដែលនៅកងចល័តហ្នឹងជួបការលំបាកនូវ ដូចជាការហូបចុកមានគេយកទៅសម្លាប់នូវ ឬក៏មិនទាន់ទេ?

រីនៈ សម្លាប់ហើយ មានសម្លាប់បណ្តើរៗហើយ ។

វណ្ណៈ សម្លាប់ហ្នឹងដោយសារមូលហេតុអី?

រីនៈ វាថាប្រវត្តិយើងទាហាន យើងនិយាយខុសមួយម៉ាត់ពីរម៉ាត់អីក៏គេយកទៅសម្លាប់ដែរ ។

វណ្ណៈ អាហ្នឹងទំនប់ហ្នឹងទំនប់៧៥មែន?

រីនៈ ចា៎!

វណ្ណៈ លើកដល់ឆ្នាំណាបានហើយ?

រីនៈ ប្រហែលជាមួយឆ្នាំបានហើយ ។

វណ្ណៈ ដល់៧៦?

រីនៈ មិនដល់មួយឆ្នាំទេ ប្រហែលជាមួយខែ ។

វណ្ណៈ លើកលឿនម្លេះ៤-៥គីឡូ ។

រីនៈ ចុះបើកម្លាំងរាប់ម៉ឺននាក់ មិនមែនកម្លាំងតិចណា៎ ចាំមើលទៅអញ្ចឹងក្បាលមនុស្សឡើងហាប់មួយតំបន់៥ ទៅគប់តែមួយកន្លែង ។

វណ្ណៈ អាហ្នឹងគេហៅតំបន់៥?

រីនៈ គេហៅតំបន់៥ ។

វណ្ណៈ កាលហ្នឹងមីងស្គាល់គណៈស្រុកគណៈអីទេ?

រីនៈ គណៈស្រុកអត់ស្គាល់ទេ ។

វណ្ណៈ តាជៀល តាអីហ្នឹងមានស្គាល់ទេ?

រីនៈ តាជៀល អត់ទេ អត់ទាន់ស្គាល់គណៈស្រុកទេកាលហ្នឹង ដល់ក្រោយមកទៀតបានឮស្គាល់ ។

វណ្ណៈ ស្គាល់ពីណាគេ?

រីនៈ គេហៅ តាក្រុក គណៈឃុំ ។

វណ្ណៈ គណៈស្រុកឬមួយក៏គណៈឃុំ?

រីនៈ		គណៈឃុំ បើស្រុកខ្ញុំអត់ស្គាល់ទេ គណៈស្រុកខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ		ចុះគណៈភូមិភាគមានដែលឮទេ?

រីនៈ		អត់ដែលស្គាល់ទេ ។

វណ្ណៈ		ចុះមានដែលឮឈ្មោះ រស់ ញឹម ទេ?

រីនៈ		មិនដែលឮទេ ។

វណ្ណៈ		អត់ដែលទេ?

រីនៈ		អត់ គេអ្នកធំយើងមិនដែលហ៊ានសួរឈ្មោះគេផង ។

វណ្ណៈ		ប៉ុន្តែក្រែងលោយើងបានដឹង ហើយបើមិនដឹងក៏មិនអីដែរ អញ្ចឹងអ្នកនៅគ្រប់គ្រង ដូចថាធ្វើទំនប់ អាហ្នឹងគេហៅទំនប់អី មានឈ្មោះទេទំនប់ហ្នឹង?

រីនៈ		គេហៅទំនប់ដើមគរ៣ដើម ខ្លះគេហៅគោករំចេក ខ្លះគេហៅដើមគរ៣ដើម ។

វណ្ណៈ		គេហៅដើមគោ៣ដើមឬគោករំចេក?

រីនៈ		ចា៎! គោករំចេក ។

វណ្ណៈ		ចុះមីងបានលើកទំនប់គោករំចេកហ្នឹងដល់ចប់ហើយហ្នង ឬក៏បានផ្លាស់ទៅកន្លែងថ្មីទៀត?

រីនៈ		ខ្ញុំលើកដល់ចប់ ។

វណ្ណៈ		នៅរហូតដល់ចប់?

រីនៈ		ចា៎! នៅដល់ចប់ ។

វណ្ណៈ		ពេលនៅហ្នឹងដូចថា មានបាយហូបគ្រប់គ្រាន់ ឬក៏បបរឬក៏យ៉ាងម៉េច?

រីនៈ		ប៉ះណាបាយ ប៉ះណាបបរទៅ ព្រឹកបាយ ល្ងាចបបរទៅ ។

វណ្ណៈ		ប៉ុន្តែអំឡុង៧/៩ហ្នឹងអត់ទាន់វេទនាទេ?

រីនៈ		ចា៎! នៅគ្រាន់ ។

វណ្ណៈ		ប៉ុន្តែមានមនុស្សខ្លះគេបានយកទៅសម្លាប់?

រីនៈ		ចា៎! មានយកទៅសម្លាប់ដូចថា និយាយខុសទៅ ហើយយើងប្រវត្តិទាហានទៅ អ្នកដែលគេសម្លាប់ហ្នឹង ។

វណ្ណៈ		ប្រវត្តិទាហានលន់ ណុល?

រីនៈ		ចា៎!

វណ្ណៈ		ចុះដល់ពេលចប់ពីគោករំចេកហ្នឹង មីងទៅណាវិញ?

រីនៈ		គេឲ្យដកស្ទូងម្តង ដល់ខែនេះគេឲ្យដកស្ទូងម្តង ។

វណ្ណៈ ដកស្ទូងនៅណា?

រីនៈ នៅវាលគោករំចេកនោះឯង ឲ្យខ្ញុំដក ដកសំណាបនោះ ហើយគាត់ទៅស្ទូងគឺស្ទូងផ្សេង ក្រុមខ្ញុំអ្នកដកផ្សេង ។

វណ្ណៈ ហើយស្ទូងហ្នឹងស្ទូងនៅគោករំចេកហ្នឹង?

រីនៈ ស្ទូងនោះជាមួយ ដកសំណាបបានមិនដឹងទៅស្ទូងណា អាខ្លះយកទៅស្ទូងនៅអារ៉ាក់បាក់ក ។

វណ្ណៈ ពេលស្ទូងហើយ មីងឃើញថាក្រោយយើងបានដកស្ទូងហើយ ឃើញថាមានស្រូវភោគផលអីបានច្រើនទេ?

រីនៈ បានច្រើនដែរ តែមិនដឹងថាស្រូវហ្នឹងទៅខាងណា បានជាហូបមិនគ្រប់ មិនដឹងថាគេដឹកទៅខាង ណាទៀត ។

វណ្ណៈ មីងនៅដកស្ទូងបានរយៈពេលប៉ុន្មានខែទៀតបានមីងទៅខាងណាទៀត?

រីនៈ ដកស្ទូងរួចបានខ្ញុំចល័តទៅ អាពេលច្រូតខ្ញុំទៅថ្មពួក?

វណ្ណៈ ច្រូតនៅថ្មពួកប្រហែលជាឆ្នាំ៧០ប៉ុន្មាន?

រីនៈ ៧៥-៧៦ហើយច្រូតនៅថ្មពួកហ្នឹង ។

វណ្ណៈ ថ្មពួកហ្នឹងច្រូត?

រីនៈ ចា៎! ខ្ញុំបកមកវិញពីច្រូតថ្មពួក ខ្ញុំមកនៅគេហៅកងវ៉ា ។

វណ្ណៈ ច្រូតកាត់នៅថ្មពួកហ្នឹងរយៈពេលប៉ុន្មានដែរ?

រីនៈ ម៉ារដូវ ប្រហែលជា៥ខែ ម៉ាច្រូតស្រូវរួចៗ ។

វណ្ណៈ ច្រូតកាត់ហ្នឹងច្រូតកាត់របៀបម៉េច គេមានផែនការដែរឬក៏យ៉ាងម៉េច?

រីនៈ គេឲ្យដូចថាចុះច្រូតអញ្ចឹងទៅ ច្រូតទៅ ច្រូតរួចអញ្ចឹងទៅយើងយប់ឡើងបោក បោកជញ្ជូនស្រូវដាក់ក្នុងជង្រុក ហើយគេដឹកខ្ញុំមកដាក់នៅកងវ៉ាវិញ ។

វណ្ណៈ អីចឹងថ្ងៃច្រូត ហើយយប់បោក?

រីនៈ ចា៎! យប់បោកស្រូវ ។

វណ្ណៈ បោកដល់ម៉ោងប៉ុន្មាន?

រីនៈ ម៉ោង១២ ។

វណ្ណៈ យូ?

រីនៈ ចា៎!យូដែរហ្នឹង ។

វណ្ណៈ អីចឹងពេលធ្វើការ ម៉ោងធ្វើការពេលព្រឹក?

រីនៈ ព្រឹកច្រូត ។

វណ្ណៈ ព្រឹកម៉ោងប៉ុន្មាន?

រីនៈ ព្រឹកម៉ោង៧ចេញហើយ ។

វណ្ណៈ ហើយម៉ោងប៉ុន្មានឈប់ហូបបាយ?

រីនៈ ម៉ោង១១ឈប់ហូបបាយ ហើយម៉ោង១យើងចាប់ផ្ដើមទៀត ។

វណ្ណៈ ហើយថ្ងៃចេញទៅម៉ោងប៉ុន្មានឈប់ ពេលល្ងាច?

រីនៈ ល្ងាចម៉ោង៥ ។

វណ្ណៈ ឈប់ហូបបាយ?

រីនៈ ចាំ! ហូបបាយរួចទៅបោកស្រូវយប់ទៀត ។

វណ្ណៈ ហូបបាយហើយម៉ោងប៉ុន្មានបានទៅបោកស្រូវ?

រីនៈ ម៉ោង៦ ។

វណ្ណៈ ឆាប់ហើយ អញ្ចឹងហូបបាយតែមួយភ្លែតទៅបោកទៀតហើយ?

រីនៈ ចាំ! ដល់ពេលល្ងិតៗចេញហើយ ឲ្យតែល្ងិតចេញទៅបោកហើយ ។

វណ្ណៈ ដល់ម៉ោង១២យប់?

រីនៈ ចាំ!

វណ្ណៈ តែនៅហ្នឹងបានរយៈពេលតែ៥ខែទេ?

រីនៈ ចាំ! នៅបាន៥ខែ ។

វណ្ណៈ មីងឈប់ពីការច្រូតបោកហ្នឹងហើយ តើមីងទៅណាទៀត?

រីនៈ ខ្ញុំមកចល័តនៅកងវ៉ា ។

វណ្ណៈ ចល័តកងវ៉ា?

រីនៈ ចាំ! គាត់គល់ ។

វណ្ណៈ អញ្ចឹងខ្ញុំចង់សួរបកបន្តិច មីងស្គាល់ទេនៅលើកទំនប់នៅត្រពាំងគោកហ្នឹងពីណាប្រធានដឹកនាំ?

រីនៈ ត្រពាំងថ្មនោះខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ អត់ទេ ខ្ញុំអត់ទាន់ចូលដល់ត្រពាំងថ្មទេ ឥឡូវត្រពាំងនេះសិន?

រីនៈ ដើមគោ៣ដើម?

វណ្ណៈ បាទ! ដើមគរ៣ដើមហ្នឹងពីណាប្រធាន?

រីនៈ អត់ស្គាល់ទេ ។

វណ្ណៈ ចុះកន្លែងច្រូតស្រូវពីណាប្រធាន កងចល័តអីហ្នឹង?

រីនៈ កងចល័តនោះឈ្មោះ តាឡេង អ៊ី! កាលដែលចល័តកន្លែងច្រូតនោះ?

វណ្ណៈ ចល័តលើកទំនប់នេះ ដើមគរ៣ដើមនេះ?

រីនៈ អត់ស្គាល់ទេ កាលហ្នឹងគេបញ្ជូនទៅខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ អីចឹងកាលច្រូតនៅថ្នពួក?

រីនៈ ប្រធានគេនោះអ្នកក្តាប់តែម្តង ។

វណ្ណៈ តែមីងស្គាល់ទេ?

រីនៈ អត់ស្គាល់ទេ គេចៅហ្វាយស្រុក ខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ ហើយចុះប្រធានគ្រប់គ្រងផ្ទាល់មីង១០នាក់១២នាក់ហ្នឹងអត់ស្គាល់ដែរ?

រីនៈ ភូមិនេះនោះយើងដាក់បញ្ចូលគ្នា មិនមែនមានតែភូមិយើងម្នាក់ណា៎ ។

វណ្ណៈ ប៉ុន្តែអ្នកដែលដូចថា ឥឡូវដល់ម៉ោងហើយ មីងចុះទៅច្រូត អ្នកដែលមកប្រាប់មីងអញ្ចឹង?

រីនៈ យោធា ។

វណ្ណៈ យោធា?

រីនៈ ចា៎! ពួកយោធា សេនាជនកាលហ្នឹង ។

វណ្ណៈ យោធាអត់ស្គាល់ទេ?

រីនៈ អត់ស្គាល់ទេ ។

វណ្ណៈ អីចឹងអត់មានកងនារីកាន់១០នាក់ ២០នាក់ ៣០នាក់ អីស៊ីវិលទេ?

រីនៈ អត់ទាន់មានទេ ។

វណ្ណៈ កាល៧៦ហ្នឹង?

រីនៈ ចា៎! ពេលទៅឆ្ងាយអញ្ចឹងពួកកងយោធាគេក្តាប់តែម្តង គេថាដល់ម៉ោងហើយ ពួកខ្ញុំចេញទៅ បានអ្នកស្រុកហ្នឹងបណ្តើរទៅច្រូតជាមួយអ្នកស្រុកទៅ ។

វណ្ណៈ យោធាបញ្ជារឲ្យធ្វើការតាំងពីលើកទំនប់ ច្រូតអីហ្នឹង?

រីនៈ ចា៎!

វណ្ណៈ ចុះដល់ពេលចេញពីច្រូតរយៈពេល៥ខែ មីងទៅកងចល័តណាមីង?

រីនៈ កងចល័ត តាស្រួច ហើយនឹង តាឡេង ពីនាក់ហ្នឹង ។

វណ្ណៈ កងចល័តនៅម្តុំណា?

រីនៈ នៅកងភ៊ា ។

វណ្ណៈ	កងវ៉ា មានតាស្រួច?
រីនៈ	ចា៎! តាស្រួច ហើយនឹងតាឡេង ។
វណ្ណៈ	តាឡេង គាត់មានតួនាទីអីគេ?
រីនៈ	គាត់គណៈស្រុក គណៈខេត្ត ចូលគណៈខេត្ត ។
វណ្ណៈ	គណៈស្រុកឬក៏គណៈខេត្ត?
រីនៈ	គណៈខេត្តតែម្ដង គេហៅចល័តតំបន់កាលហ្នឹង ។
វណ្ណៈ	មីងនៅលើទំនប់កងវ៉ាហ្នឹងរយៈពេលប៉ុន្មានដែរ?
រីនៈ	ខ្ញុំនៅបានមួយឆ្នាំ ។
វណ្ណៈ	អាហ្នឹងយើងអត់ទាន់ដល់ទំនប់ត្រពាំងថ្មទេ?
រីនៈ	អត់ទេ ទាល់តែខ្ញុំបកពីនោះមកបានចូលទំនប់ត្រពាំងថ្ម ។
វណ្ណៈ	អីចឹងឥឡូវយើងទៅទំនប់កងវ៉ា ទំនប់កងវ៉ាហ្នឹងគេលើករបៀបម៉េចដែរ?
រីនៈ	គេលើកម្នាក់១០ម៉ែត្រ គេវាស់ម៉ែត្រទៅ អាទំនប់តូចៗយើងហ្នឹង ។
វណ្ណៈ	មិនមែនលើកម៉ែត្រគីបទេ?
រីនៈ	អត់ទេ អានោះវាស់ម៉ែត្រយើងតែម្ដង ។
វណ្ណៈ	វាស់ម៉ែត្រ?
រីនៈ	ចា៎! ម្នាក់១០ម៉ែត្រ ។
វណ្ណៈ	អាហ្នឹងគេហៅភ្លឺស្រែ?
រីនៈ	ភ្លឺ ។
វណ្ណៈ	លើកភ្លឺស្រែទេ មិនមែនទំនប់ទេ?
រីនៈ	ចា៎! បើថ្ងៃណានេះទៅមកធ្វើចំការ ផុតចំការបានគេប្រើឲ្យទៅលើកភ្លឺ ។
វណ្ណៈ	មួយថ្ងៃ១០ម៉ែត្រ?
រីនៈ	ចា៎! ១០ហ្នឹងយើងរួចប៉ុណ្ណាយើងឡើងមកកន្លែងវិញទៅ ។
វណ្ណៈ	បើអត់ហើយអត់បានទេ?
រីនៈ	អត់ហើយអត់បានទេ ត្រូវតែហើយ បើអត់ហើយអីចឹងមានគេមកជួយទៅណា៎ ឲ្យរួចទាំងអស់គ្នា ។
វណ្ណៈ	ទទឹងប៉ុន្មាន?
រីនៈ	ទទឹងកន្លះម៉ែត្រទេ ។

វណ្ណៈ	អីចឹងទាំងស្រីទាំងប្រុស១០ម៉ែត្រដូចគ្នា ឬក៏កម្លាំងប្រុសលើកលើស ហើយកម្លាំងស្រីលើកតិច?

រីនៈ	អត់ទេ លើកដូចគ្នាទាំងអស់។

វណ្ណៈ	នៅកន្លែងលើកភ្លឺស្រែហ្នឹងពីណាប្រធាន មីងដឹងទេ?

រីនៈ	កាលហ្នឹងប្រធានគឺតាស្រួច ហើយនឹងតាឡេង ហ្នឹងឯង គាត់អ្នកប្រធានក្តាប់បន្តៗគ្នា។

វណ្ណៈ	តែអាហ្នឹងលើកទំនប់ហ្នឹង លើកភ្លឺស្រែហ្នឹងក្នុងស្រុកឃុំហ្នឹងដែរ?

រីនៈ	ចា៎! នៅភូមិនោះ មិនមែននៅនេះទេ នៅស្វាយកងវ៉ាយើងនេះ។

វណ្ណៈ	នៅស្វាយ?

រីនៈ	ចា៎! លើកទៅនោះ។

វណ្ណៈ	អីចឹងអត់បានមកលេងផ្ទះសម្បែងទេ?

រីនៈ	ចា៎! មកលេងនេះខ្ញុំគ្រុនញាក់ខ្ញុំរត់មកផ្ទះ ដល់ហើយគេបញ្ជូនខ្ញុំឲ្យទៅត្រពាំងថ្មតែម្តង។

វណ្ណៈ	ពេលឆ្នាំណាមីងរត់មកនេះ មីងមានចាំទេពេលរត់មកផ្ទះ?

រីនៈ	ឆ្នាំមុនដែលប្រូតត្រពាំងថ្មហ្នឹង ដូចថាលើកទំនប់ត្រពាំងថ្មនេះរួច ដល់ពេលក្រោយនេះបានចប់មិនដឹងឆ្នាំប៉ុន្មានខ្ញុំអត់ចាំផង។

វណ្ណៈ	ចុះលើកត្រពាំងថ្មប៉ុន្មានឆ្នាំ?

រីនៈ	ដូចថាត្រពាំងថ្មលើកឆ្នាំនេះ ដល់ពេលឆ្នាំក្រោយបានចប់។

វណ្ណៈ	អញ្ចឹងប្រហែលជាពាក់កណ្តាល៧៧?

រីនៈ	ប្រហែលចូល៧៨ហើយដឹង។

វណ្ណៈ	៧៨?

រីនៈ	ចា៎! ៧៨ ព្រោះ៧៩យើងចប់។

វណ្ណៈ	អីចឹងមីងនៅលើកភ្លឺស្រែហ្នឹងឆ្នាំ៧៧?

រីនៈ	ចា៎!

វណ្ណៈ	រត់មកផ្ទះ?

រីនៈ	រត់មកផ្ទះ បញ្ជូនទៅត្រពាំងថ្ម។

វណ្ណៈ	មីងឈឺដែរ?

រីនៈ	ឈឺ គ្រុនញាក់។

វណ្ណៈ	ឈឺដល់ពេលជា គេបញ្ជូនមីងទៅត្រពាំងថ្ម?

រីនៈ ចា៎!

វណ្ណៈ អ្នកការបញ្ជូនមីង?

រីនៈ មិនទាន់នឹងបានដារមែនទែនដងវាបញ្ជូនខ្ញុំទៅ ឲ្យវាទៅងាប អាយុវាថ្ងៃវាមិនព្រមងាប់ ។

វណ្ណៈ ពេលបញ្ជូនមីងទៅត្រពាំងថ្មហ្នឹង មីងមានតវ៉ាគេថាខ្ញុំនៅឈឺទេ?

រីនៈ ខ្ញុំប្រាប់អីចឹងដែរ ខ្ញុំថាខ្ញុំនៅឈឺ ពុកអើយ! កាលហ្នឹងហៅតែពុកណា៎ ។

វណ្ណៈ ពីណាគេ?

រីនៈ កាលហ្នឹង តាឈួង ។

វណ្ណៈ តាឈួង ហ្នឹងគាត់ប្រធានភូមិ?

រីនៈ ចា៎! តាឈួង គាត់ប្រធានភូមិ ។

វណ្ណៈ គាត់នៅទេ?

រីនៈ គេសម្លាប់ចោលហើយ សម្លាប់មួយតំណរៗ ។

វណ្ណៈ ស្លាប់ឆ្នាំ៧០ប៉ុន្មានដែរ?

រីនៈ ស្លាប់ពេលជិតចប់ហើយ ។

វណ្ណៈ ពេលពួកនិរតីមកមែន?

រីនៈ ចា៎! និរតីមកក្រោយយកទៅសម្លាប់ចោល ។

វណ្ណៈ ពេលនិរតីចូលមកក្នុងភូមិមានស្គាល់ទេ ពួកនិរតីហ្នឹងមីងស្គាល់គណៈកង គណៈឃុំ គណៈស្រុកអីទេ?

រីនៈ ស្គាល់តែឈ្មោះ វ៉ាន ។

វណ្ណៈ វ៉ាន ហ្នឹងធ្វើអីគេ?

រីនៈ ប្រធាននៅក្នុងភូមិនេះឯង ។

វណ្ណៈ មកពីនរតីមែន?

រីនៈ ចា៎!

វណ្ណៈ ចុះមីង ពេលមីងទៅលើកទំនប់ត្រពាំងថ្មហ្នឹង ពេលមីងទៅដល់ភ្លាមហ្នឹងមីងឃើញសភាពយ៉ាងម៉េច ទៅដល់មានឃើញគេលើកហើយពីមុនមកទេ ឬទៅដល់ចាប់ផ្តើមហ្មង?

រីនៈ ទៅដល់ចាប់ផ្តើមទាំងអស់គ្នាតែម្តង ។

វណ្ណៈ ទំនប់ត្រពាំងថ្មចាប់ផ្តើមលើកពីឆ្នាំ៧៨ទៅ?

រីនៈ	ចា៎! ៧៨ហ្នឹងហើយ កាលនោះខ្ញុំវាក្មេងឆ្នាំផង មិនសូវចាំផងកាលនោះ ខ្ញុំចំណាំបានតែលើកត្រពាំងថ្មរួចឆ្នាំនេះ ឆ្នាំក្រោយទៅជង្រៀបក្ដាមស្រុកចប់បណ្ដោយ ។

វណ្ណៈ	ឆ្នាំ៧៨ រហូតដល់៧៩ហ្នឹង?

រីនៈ	នៅក្នុងឆ្នាំ៧៨ រួចនៅក្នុងឆ្នាំហ្នឹងតែម្ដង ។

វណ្ណៈ	អ៊ីចឹងលើកតែប្រហែលជាមួយឆ្នាំចប់?

រីនៈ	ចា៎!

វណ្ណៈ	ត្រពាំងថ្មហ្នឹង ទំនប់ហ្នឹងលើកហើយជាស្ថាពរហ្នង?

រីនៈ	ចា៎! លើកហើយ ។

វណ្ណៈ	ទំនប់ហ្នឹងធំទេ?

រីនៈ	ធំណាស់ ខ្ទង់បើកឡាន២មិនទើសគ្នាផង កម្ពស់១៦ម៉ែត្រ ទទឹង២០ម៉ែត្រហើយ បើត្រង់ណាទំនាបចេះវាដាក់១៦ ត្រង់ណារាងទើលដីៗវាដាក់៨ម៉ែត្រ វាតាមទំនាបតាមអី ។

វណ្ណៈ	បាទ!ចុះបណ្ដោយ?

រីនៈ	អូ៎!បណ្ដោយវែងណាស់ មិនដឹងជាប៉ុន្មានទេ បណ្ដោយឆ្ងាយណាស់មិនដឹងជាប៉ុន្មានទេ ។

វណ្ណៈ	ចុះបើបណ្ដោយឆ្ងាយណាស់ លើកតែមួយឆ្នាំហើយ លឿនម៉្លេះមីង?

រីនៈ	ចុះបើគ្នាច្រើន ។

វណ្ណៈ	គ្នាប៉ុន្មានទៅ?

រីនៈ	មា៉តំបន់នេះចូលទាំងអស់គ្នា ហើយខាងនេះក៏លើកគួប ខាងនេះក៏លើកគួប លើកប្រជល់គ្នាម៉ោ ។

វណ្ណៈ	ប៉ុន្មានតំបន់ទៅលើកនៅហ្នឹង?

រីនៈ	មា៉តំបន់ៗ តំបន់៥ តំបន់៦ ទៅទាំងអស់ទាំងចាស់ទាំងក្មេងអី វ៉ៃយកណ្ដាលនឹងនារី ។

វណ្ណៈ	មានយុវជន មានចាស់ មានក្មេង អ្នកមានគ្រួសារហើយទាំងអស់?

រីនៈ	អ្នកមានគ្រួសារហើយ ដូចគេដាក់មា៉វគ្គអ្នកមានគ្រួសារទៅណា៎ ប៉ុនយុវជននឹងនារីនេះច្រើន ។

វណ្ណៈ	មនុស្សរាប់ច្រើនទេ ប្រហែលប៉ុន្មាន?

រីនៈ	អូ៎!រាប់ម៉ឺននាក់ គ្រាន់តែមើលតែមនុស្សហ្នឹងវាចង់ពុលបាត់ទៅហើយ ។

វណ្ណៈ	កាលហ្នឹង កាលលើកត្រពាំងថ្មមានប្រជាជនថ្មី ជម្លៀសម៉ោពីភ្នំពេញទៅលើក?

រីនៈ ចាំ! មានហើយ កាលនោះទៅជុំគ្នា ទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់ បានជាបានកម្លាំងទៅច្រើន ។

វណ្ណៈ អីចឹងទៅទាំងកសិករយុវជនអី អីចឹងដល់ពេលហ្នឹងគេលែងសម្រុកធ្វើស្រែចំការហើយ គេសម្រុកទៅលើកទំនប់វិញចុះ?

រីនៈ ស្រែចំការអ្នកភូមិចាស់ៗនេះធ្វើ ហើយដូចក្មេងៗដកទៅលើកនោះ ។

វណ្ណៈ ចុះមីអចថាអ្នកកសិករមានប្រពន្ធអីអាចទៅដែរ?

រីនៈ ប្រពន្ធដូចអ្នកមិនទាន់មានកូនអីទៅដែល ប៉ុនគេទៅអត់បានយូរដូចនារីយុវជនទេ បើនារីយុវជននោះនៅតស៊ូទាល់តែរួច ។

វណ្ណៈ ទំនប់អាងត្រពាំងថ្មហ្នឹង ដូចថាការហូបចុកយ៉ាងម៉េចទៅ?

រីនៈ អ៊ូ!ខ្វះខាត ។

វណ្ណៈ ហូបបបរ?

រីនៈ បាយដែរ ប៉ុនអត់មានម្ហូបដែរធ្វើម៉េចមានកម្លាំងលើក បាយម្តងម៉ាវែក ប៉ះថ្ងៃណាទៅបបរឲ្យយើងទៅ?

វណ្ណៈ ចុះមានមនុស្សស្លាប់ដោយសារតែអត់បាយទេ?

រីនៈ មានស្លាប់នឹងអត់បាយ ស្លាប់នឹងឈឺ ស្លាប់នឹងវ៉ៃចោលក៏ច្រើន ។

វណ្ណៈ វ៉ៃចោលដែរ?

រីនៈ ចាំ!

វណ្ណៈ មានកំហុសអីបានវ៉ៃចោល?

រីនៈ មិនដឹងរឿងដែរ ដូចថាយើងឈឺមិនទៅចេះ វាគាមដាន១ដង-២ដងទៅ ថាយើងទៅមិនទៅអីយកទៅវ៉ៃចោលទៅ ថាយើងខ្ជិលមិនទៅធ្វើការ ស្រេចតែចិត្តវាទៅ ហើយវាឲ្យវែកម្នាក់៣ម៉ែត្រគីបឲ្យឆាប់រួច ៣ម៉ែត្រឲ្យឆាប់រួចបើមិនរួចវាអត់ឲ្យស៊ីបាយទេ ហើយអ្នកខ្លាចវាចេះតែវែកទៅ ។

វណ្ណៈ មីងវែកបានដែរ៣ម៉ែត្រគីប?

រីនៈ ដូនកាលខ្ញុំវែករួច ដូនកាលខ្ញុំវែកអត់រួចទេ កាលនោះខ្ញុំនៅឈឺ ។

វណ្ណៈ បាទ!៣ម៉ែត្រគីបច្រើន?

រីនៈ ច្រើនណាស់ ដូនកាលខ្ញុំវែកបានតែ២ម៉ែត្រគីបទេ ។

វណ្ណៈ អីចឹងដូចថាយើងអាចវែកចូលគ្នា២នាក់ ឲ្យបាន៦ម៉ែត្រគីបបានទេ?

រីនៈ ធ្វើអីចឹងដូចជាវាឃើតទៅវិញ ទាល់តែរែកប្រើកម្លាំងយើងរៀងៗខ្លួន ។

វណ្ណៈ អីចឹង! បើយើងដាក់ចូលគ្នា?

រីនៈ ឃើតទៅវិញទេ ទាល់តែរែកម្នាក់ៗឯង ។

វណ្ណៈ អីចឹង! កាប់ខ្លួនឯង រែកខ្លួនឯង?

រីនៈ ចា៎!

វណ្ណៈ ចុះបើសិនជាថ្ងៃហ្នឹងយើងអត់ហើយ៣ម៉ែត្រគីប តើគេធ្វើម៉េចទៀត?

រីនៈ បើមិនហើយ៣ម៉ែត្រគីបវាស្រែកថា កុំអាលហូបបាយ ប៉ុននៅតែលួចទៅហូប ហូបបាយរួចមានកម្លាំងទៅរែកទៀតៗ ដល់ម៉ោង៩ ម៉ោង១០បានវាឲ្យយើងទៅដេក អាហ្នឹងវាហីទៅ ។

វណ្ណៈ អ្ហូ!ឱបមាថា ឥឡូវយើងរែកម៉ោង៥អត់ហើយទេ វាស្រែកថាអត់ឲ្យទៅញាំុបាយទេ?

រីនៈ ចា៎!អត់ឲ្យទៅញាំុទេ ។

វណ្ណៈ ប៉ុន្តែយើងអាចទៅញាំុបាន?

រីនៈ តែលួចទៅទេ អត់មាននេះ ទុកតែដងរែកនឹងនេះទៅ លួចទៅៗស៊ីបាយ ទៅស៊ីបាយមានកម្លាំងរួចបានមករែកទៀតដូចថា ដល់ម៉ោង៨ ម៉ោង៩ចេះបានវាឲ្យយើងទៅដេកកន្ទេង ។

វណ្ណៈ អ្ហូ!អីចឹងត្រូវតែហើយហ្នុង?

រីនៈ អត់ហើយ ដួនកាលហើយ ដួកកាលអត់ហើយដែរ ។

វណ្ណៈ អត់ហើយ ប៉ុនយើងធ្វើដល់ម៉ោង៨-៩យប់ទៀតនោះ ។

រីនៈ ចា៎! ម៉ោង៨-៩យប់ចេះទៅបានវាឲ្យយើងទៅដេក ស្រែកឡើងវាវាស់សារថ្មីឲ្យយើងទៀត ។

វណ្ណៈ អ្ហូ!អីចឹងបានន័យថា ៣ម៉ែត្រគីបហ្នឹងត្រូវតែហើយ ទោះម៉ោង១០ក៏ឲ្យទៅធ្វើដែរ?

រីនៈ ចា៎!

វណ្ណៈ អីចឹងទេ មិនមែនទេ?

រីនៈ ចា៎!

វណ្ណៈ អ្នកណាហើយពីថ្ងៃទៅដេកទៅ?

រីនៈ ទៅដេកទៅ អ្នកមិនហើយក៏នៅរែកហ្នឹងទៅ ម៉ោង៨យប់ ។

វណ្ណៈ អីចឹងយើងអាចទៅបន្ទំហូបបាយបាន ដោយសារមនុស្សច្រើនពេកឬក៏?

រីនៈ ចា៎! ដូចមនុស្សច្រើន ដូចថាអីចឹងទៅ វាស្រែកអីចឹងទៅ ខ្ញុំទម្លាក់តែចបអីចេះទៅ អៀរៗចូលទៅស៊ីសិន យើងស៊ីឲ្យមានកម្លាំងចេះម៉ោ បានម៉ោរែកទៀត ។

វណ្ណៈ  ចុះដូចអ្នក១៧មេសាអ្នកភ្នំពេញ គ្នាអត់សូវចេះកាប់គាស់វែកអីអីចឹងធ្វើយ៉ាងម៉េចទៅ?

រីនៈ  ទៅទាំងអីចឹងនោះឯង ទាំងវេទនានោះឯង ទាំងត្រដរនោះឯង ហើយដូចថាទៅហើយគ្នាឈឺគ្នាទៅមិនរួច វាថាយើងស្ទាក់អារម្មណ៍វាសម្លាប់យើងចោលទៅក៏មានដែរ ។

វណ្ណៈ  បាទ!ចុះអ្នកដែលគ្រប់គ្រងនៅអាងត្រពាំងថ្ម មីងស្គាល់ទេ?

រីនៈ  កាលនោះតាម៉ោង តាវ៉ាល់ ហ្នឹងឯងអ្នកគ្រប់គ្រង ដល់វាបណ្ដើរគ្នាអីចឹងក៏ ។

វណ្ណៈ  មានតាម៉ោង តាវ៉ាល់?

រីនៈ  ចា៎! ហើយទឹកកាលនោះ ទឹកក្នុងម៉ាវែកត្រូវ៣០នាក់ ហើយវែកបំពុងយើងវែង១នេះ២ឆ្នាំងដៃ អាបំពុងឬស្សីយើងកាប់២ឆ្នាំងដៃចេះប្រេក ហើយទឹកហ្នឹងមិនដឹងជានៅណាទេ ដើររក យកមកដល់គ្នា១០អីចេះ ចែកបានម្នាក់ម៉ាផ្ទិល សឹងតែវាល់ស្លាបព្រាចែកគ្នា ។

វណ្ណៈ  អីចឹងសូម្បីតែទឹកអត់មានហូបទៀត?

រីនៈ  ចា៎! ទឹកអត់មានហូប ។

វណ្ណៈ  អីចឹងប្រឡាយហ្នឹង កន្លែងប្រឡាយហ្នឹងអត់មានទឹកទេ?

រីនៈ  អត់ទេ! អត់មានទេ ដីស្ងួត ហើយអ្នកដែលលើកថាមិនបានហីចុះ ឲ្យតែបានទឹក ។ ចុះពូគិតមើលពីព្រឹកចេះម៉ាផ្ទះចេះ១០នាក់ យកមកវាល់ចែកគ្នា សឹងថាដាក់ស្លាបព្រា ។

វណ្ណៈ  អីចឹងងូតទឹកងូតអីគ្មានបានងូតទេ?

រីនៈ  គ្មានបានងូតទេ កន្ទះខែមិនទាន់បានងូតម្ដងផង មិនបាច់ទៅដល់ងូតទេគ្រាន់តែលាភ ដីកឲ្យតែបានជាប់កក៏មិនបានផង ។

វណ្ណៈ  ងូតគ្រាន់តែលាងៗខ្លួនទេ?

រីនៈ  អត់ឲ្យលាងទេ គ្មានបានទឹកលាងខ្លួនទេ គ្រាន់តែបានម៉ាដីកនោះឯង ម៉ាជ្រាបកហ្នឹង ។

វណ្ណៈ  អីចឹងអត់ងូតទឹកម៉ោរហូត?

រីនៈ  ចា៎! មិនបាច់ងូតទេ លុបមុខគ្មានទឹកនឹងលុបទៀតនោះ ហើយខ្លួននេះចេញចៃទៀតនោះ ចេញចៃតាមអាវ តាមសំពត់ទៀតនោះ ។

វណ្ណៈ  អីចឹងអត់មានដូចថា មានថ្ងៃណានេះ ប៉ុនជួនកាលត្រូវភ្លៀងអីបានងូតទេ?

រីនៈ  អត់មានភ្លៀងទេ កាលហ្នឹងខែចេត្រ អត់មានភ្លៀងទេ ។

វណ្ណៈ  កើតចៃទៀត?

រីនៈ  ចា៎! កើតចៃចេញពេញតែខ្លួន សូម្បីតែទឹកបៀត មើលទៅប្រហែលរោងម៉ាស៊ីនកិនស្រូវហ្នឹង ក៏វាអត់ឲ្យយើងទៅដែរ អត់ឲ្យទៅទេ

ដល់ខ្ញុំអត់ខ្វាំងនាំគ្នាថាដើរទៅផ្លូតវាអត់ឲ្យទៅទេ ហៅ មកវិញឲ្យម៉ោនោកន្លែង បើទៅបានៗតែអ្នកវែកទឹកឲ្យផឹកទេ អាហ្នឹងអាចទោជនបាន កំសត់ អារឿងទឹកនេះកំសត់មែនទែនហើយ ។

វណ្ណៈ អ៊ីចឹងមីងសង្កេតមើលទៅ ក្នុងការលើកអានត្រពាំងថ្មហ្នឹង តើអ្នក១៧មេសាស្លាប់ច្រើនជាង ឬក៏អ្នកមូលដ្ឋានអីស្លាប់ច្រើនជាង?

រីនៈ ស្លាប់ស្មើគ្នាកាលហ្នឹង។ ប៉ុនថាអ្នកភ្នំពេញគេមកក្រែលក៏ស្លាប់ក្រែល យើងនេះក៏ស្លាប់ក្រែល ដែរ។

វណ្ណៈ បាទ! អ្នកភ្នំពេញជម្លៀសម៉ោនេះច្រើនទេ?

រីនៈ ចា៎! ម៉ោច្រើនដែរ។

វណ្ណៈ អ៊ីចឹងបន្ទាប់ពីគាវ៉ាល់ គាអីគ្រប់គ្រងពីលើហ្នឹង តើអ្នកគ្រប់គ្រងផ្ទាល់ គ្រប់គ្រងតាមក្រុមតាមអីក្រុមមីងត្រូវមានអ្នកគ្រប់គ្រង ឧបមាថា១០នាក់ ១២នាក់ មានប្រធាននារីអីមីងស្គាល់ទេកាលហ្នឹង?

រីនៈ កាលហ្នឹងមានប្រធាននារី។

វណ្ណៈ ប្រធានកងចល័ត?

រីនៈ ចា៎!

វណ្ណៈ ពីណាគេ?

រីនៈ ពួក គីម រស់ អ្នកស្រុកគ្នាឯងហ្នឹងអ្នកក្តាប់ធម្មតា។

វណ្ណៈ តែសព្វថ្ងៃគាត់នៅរស់ទេ?

រីនៈ ចា៎!នៅរស់ អានេះដូចតែអ្នកគេបញ្ជាឲ្យយើងក្តាប់ ត្រួតត្រាយើង។

វណ្ណៈ ហ្នឹងហើយ។ អត់មានប្រធាននារីអីទេ?

រីនៈ ក្តាប់បន្តគ្នា ដូច១០នាក់ៗអីចឹងក្តាប់បន្តគ្នា។

វណ្ណៈ បាទ!ចុះមីងដូចថា ក្រៅពីចែកម៉ែត្រគ្នា៣ម៉ែត្រក្នុង១ថ្ងៃហ្នឹង តើអង្គការមានបន្ថែមលើសហ្នឹង ទៀតទេ ឬក៏អត់ទេ?

រីនៈ អត់ទេៗ! អត់មានទេ។

វណ្ណៈ ត្រឹម៣ម៉ែត្រហ្នឹងហើយ ដឹងតែទៀងមួយថ្ងៃ៣ម៉ែត្រៗអីចឹងហ្នង?

រីនៈ ចា៎!

វណ្ណៈ ហើយមានឃើញគណៈប្រតិភូធំអី បើកឡានចុះម៉ោប្រជុំប្រុក៏ម៉ោត្រួតពិនិត្យអីទេ នៅអាង ហ្នឹង?

រីនៈ អត់ទេ! មានតែ រស់ ទេ ។ យើងអ្នកវែកគិតតែពីវែកទៅ ។

វណ្ណៈ បាទ! ចុះមីងមានដឹងថា ចន្លោះពេលហ្នឹងដែលខាងនិរតីម៉ោ មានចាប់អ្នកកម្មាភិបាលចាស់ៗ ក្នុង ភូមិដែលគាត់ អ្នកមានស្រុកភូមិអីនៅហ្នឹង ម៉ោចាប់មីងដឹងទេ?

រីនៈ ចាប់ៗនៅនឹងមុខហ្នឹង ខ្ញុំឃើញដែលហ្នឹង ចាប់ប្រធានភូមិ ។

វណ្ណៈ ចាប់ប្រធានភូមិឈ្មោះអី?

រីនៈ ឈ្មោះតា ប៊ីន ។

វណ្ណៈ ប្រធានភូមិ?

រីនៈ ប្រធានភូមិមានអ្នកកំណើតនេះទេ អ្នកម៉ោពីឆ្ងាយ ឲ្យម៉ោត្រួតនៅនេះ អ្នកសៀមរាប ។

វណ្ណៈ ឈ្មោះតាអី?

រីនៈ តាប៊ីន វាចាប់នឹងមុខពួកខ្ញុំដែលកំពុងស្ទូង ។

វណ្ណៈ ឆ្នាំណា?

រីនៈ អាឆ្នាំដែលយើងរៀបចំហើយៗ ។

វណ្ណៈ អ្ហូ!៧៨ហើយ ដែលនិរតីចូលម៉ោហ្នឹង?

រីនៈ ចាំ!

វណ្ណៈ ចុះមីងគណៈតំបន់ គណៈស្រុកអីមីងអត់ស្គាល់ទេ?

រីនៈ អត់ស្គាល់ទេ ។

វណ្ណៈ អត់ស្គាល់ យាយថែម ទេ?

រីនៈ យាយថែម ក្តាប់តែខាងចល័តហ្នឹងឯង ។ យាយថែម ជីមិនស្គាល់ យាយថែម ក្តាប់ខាង ចល័ត ។

វណ្ណៈ ចល័តណា ចល័តត្រពាំងថ្មហ្នឹងមែន?

រីនៈ ចាំ! ចល័តត្រពាំងថ្មហ្នឹង ។

វណ្ណៈ ចុះមីងថាអត់ស្គាល់?

រីនៈ (សើច) ភ្លេចឈ្មោះយាយថែម ខ្ញុំរកនឹកមិញនោះ ខ្ញុំរកនឹកអត់ឃើញ ។ យាយថែម ហ្នឹង ឮតែឈ្មោះ មុខអត់បានឃើញទេ ។ ខ្ញុំថាឈ្មោះអីៗ រកនឹកមិញអត់ឃើញ ។

វណ្ណៈ កាន់កងចល័តត្រពាំងថ្ម?

រីនៈ ចា៎!

វណ្ណៈ គាត់ដែលម៉ោប្រជុំនៅអាងត្រពាំងថ្មហ្នឹងទេ?

រីនៈ គេប្រជុំៗតែអ្នកធំ យើងអ្នករែកឲ្យតែឃើញ គ្រាន់តែមុខយាយថែម ហ្នឹងមិនដែលឃើញផង ខ្ញុំមិនដែលបានជួបទេ។

វណ្ណៈ អ៊ីចឹងកាលដែលយាយថែម មកកាន់កាប់ហ្នឹង មនុស្សកាន់តែស្លាប់កាន់តែច្រើនយ៉ាងម៉េចដែរ?

រីនៈ ឆ្នាំហ្នឹងស្លាប់ច្រើនណាស់ ឆ្នាំហ្នឹង។

វណ្ណៈ ដូចថាស្លាប់ហ្នឹងភាគច្រើនដោយការអត់អាហារ ឬការយកវ៉ៃចោល?

រីនៈ ជួនកាលស្លាប់ដោយអត់អាហារ ជួនកាលស្លាប់ដោយឈឺ ជួនកាលយកទៅវ៉ៃចោល។

វណ្ណៈ មីងដែលឃើញផ្ទាល់ចាប់យកទៅវ៉ៃចោលទេ ប៉ុន្មានដងដែរ?

រីនៈ ទឹមឃើញតែតា ប៊ីន ម្នាក់ទេ។

វណ្ណៈ តាប៊ីន ម្នាក់ទេ?

រីនៈ ចា៎!

វណ្ណៈ គេចាប់ៗមុខមនុស្សច្រើនគ្នាដែរ?

រីនៈ ចា៎!

វណ្ណៈ គេចងគេអីឬអត់?

រីនៈ ចាប់ពន្ធ័ធ្វើស្លាបសេកទៅ វាចងវាបណ្តើរចូលម៉ោភូមិនេះម៉ោ។

វណ្ណៈ អកដែលចាប់ហ្នឹង ជាយោធាឬកងឈ្លប?

រីនៈ កងនិរតី។

វណ្ណៈ និរតី?

រីនៈ ចា៎!ពួកនិរតី។

វណ្ណៈ ប៉ុន្តែពួកឈ្លបពួកអីហ្នឹង?

រីនៈ ពួកកងនិរតីហ្នឹងឯង អត់មានឈ្លបទេ ពួកកងនឹងសុទ្ធតែម្តង។

វណ្ណៈ ពួកនិរតី?

រីនៈ ចា៎!

វណ្ណៈ មានកាំភ្លើងទេ?

រីនៈ មាន ឃើញគេចាប់អីចឹងពួកខ្ញុំខ្លាច នាំគ្នាគេចមុខបាត់អស់ តែចាប់ចងពទ្ធ័ស្លាបសេករួចវានាំគាត់ចូលម៉ោនេះម៉ោ មិនដឹងវាយកទៅណា ។

វណ្ណៈ តាប៊ីន ហ្នឹងមានស្រែកទេ?

រីនៈ ស្រែកឲ្យជួយ គ្មានអ្នកណាហ៊ានជួយ គ្មានអ្នកណាហ៊ានទៅបៀតបើគេចាប់អីចឹងហើយ ។

វណ្ណៈ មីងដឹងថា តាប៊ីន ហ្នឹងគេចាប់បញ្ជូនទៅកន្លែងណាអីកន្លែងណាទេ?

រីនៈ អត់ដឹងទេ តែម៉ោវាបញ្ជូនម៉ោភូមិចេះទៅ ខ្ញុំនៅស្ងួននោះអត់ដឹងទេថាយកទៅខាងណា ។

វណ្ណៈ បាទ! នៅខាងតំបន់៥មីងរស់នៅហ្នឹង តើមីងមានដឹងថាគុកសន្តិសុខនៅកន្លែងណាទេដែលគុក គេសម្រាប់ដាក់មនុស្ស?

រីនៈ គុកដាក់អ្នកទោសនៅតំបន់៥?

វណ្ណៈ បាទ!

រីនៈ ហៅភ្នំអីនៅម្តុំហ្នឹង ភ្នំត្រយ៉ូងឬភ្នំស្តីទេ យកទៅដាក់នោះឯង ។

វណ្ណៈ គុកសន្តិសុខ?

រីនៈ ចា៎! តែនៅភ្នំជ្រាប់ នេះមួយដែរដាក់ម៉ាកន្លែង ។

វណ្ណៈ ភ្នំអីគេ?

រីនៈ ភ្នំជ្រាប់មួយ ភ្នំត្រយ៉ូងខាងកើតនេះ ។

វណ្ណៈ មានចំងាយឆ្ងាយពីហ្នឹងទេ?

រីនៈ ឆ្ងាយដែរ ភ្នំលាប ម៉ាជួរនោះឯងដែលចំងាយ ។

វណ្ណៈ ភ្នំត្រយ៉ូង ភ្នំលាបទៀត?

រីនៈ ទេ!បៀតគ្នានោះឯង ភ្នំហ្នឹងបៀតគ្នានោះឯង ។

វណ្ណៈ អ៊ូ!គុកសន្តិសុខមាន២កន្លែង?

រីនៈ ចា៎!មាន២កន្លែង ។

វណ្ណៈ មីងមានដឹងថាពីណាជាប់គុកហ្នឹងហើយ បានរួចខ្លួនមកដល់សព្វថ្ងៃនេះទេ?

រីនៈ អត់មានទេ!មានតែអ្នកនេះ គេហៅអ្នកនោះទេ អត់មានអ្នកក្នុងភូមិនេះទេ ។ អ្នកនៅពាងអានោះគេបានជាប់ផ្ទាល់ អានោះចល័តជុំគ្នានឹងខ្ញុំ គេនៅជាប់ផ្ទាល់ អានេះតែងាប់រស់យ៉ាងណាអត់ទេ អានោះជាប់ប្រទល់ហើយ ។

វណ្ណៈ បាទ! អ្នកដែលជាប់គុកហ្នឹងមីងគិតថាប្រហែលជាស្លាប់ ឬបានរស់មើលទៅ?

រីនៈ គ្មានរស់ទេ តែជាប់ហើយដឹងតែស្លាប់ហើយ ។

វណ្ណៈ	ជាប់គុកដឹងតែស្លាប់ហ្មង?

រីនៈ	ចា៎! រស់បានមួយនាក់ ដែលអានោះដែលចប់ហើយវ៉ៃចោលអត់ទាន់ តែជាប់ហើយដឹងតែស្លាប់ហើយ ។

វណ្ណៈ	បាទ! ហើយភាគច្រើនទៅពួកអ្នក១៧មេសា ឬពួកណាជាប់ហ្នឹង?

រីនៈ	ពួកយើងអ្នកភូមិខ្លះ អ្នកម៉ោពីខាងភ្នំពេញនោះខ្លះ ។

វណ្ណៈ	បាទ!ចុះយាយថែម គាត់ម៉ោបញ្ជាផ្ទាល់ គាត់កាចយ៉ាងម៉េចមីងដឹងទេ?

រីនៈ	អត់ទេ ។

វណ្ណៈ	អត់បានដឹងទេ?

រីនៈ	ចា៎!គ្រាន់តែគាត់ម៉ោបណ្ដើរៗគ្នា ម៉ាតំណរៗ ។ យាយថែម គាត់បញ្ជាតាមឃុំ ឃុំក៏បញ្ជាតាមភូមិតាមកងហ្នឹង បណ្ដើរៗគ្នាចុះម៉ោ ។

វណ្ណៈ	អញ្ចឹងគេចាប់ រស់ ញ៉ឹម ចាប់តាជៀល ចាប់តាបាល់ មីងមានដែលដឹងទេ?

រីនៈ	អត់ដឹងទេ! មិនដែលឲ្យដឹងទេវាលាក់ការល្អណាស់ ។

វណ្ណៈ	ចុះដល់ពេលក្រោយ៧៩ម៉ោ តើគេមានធ្វើពិធីគោរព វិញ្ញាណខ័ណ្ឌឬក៏គាស់សាកសពយកទៅដាក់តំកល់នៅវត្តណា មានទេនៅក្នុងភូមិ?

រីនៈ	ដែលចប់ហើយ?

វណ្ណៈ	ចប់ហើយ៧៩ហ្នឹង?

រីនៈ	គេគាស់ដាក់អាភ្នំជញ្ជាំង ។

វណ្ណៈ	ភ្នំអីគេ?

រីនៈ	ភ្នំជញ្ជាំង គាស់ដាក់ភ្នំជញ្ជាំង ធ្វើបុណ្យនៅភ្នំជញ្ជាំង ។

វណ្ណៈ	ភ្នំជញ្ជាំងឆ្ងាយពីនេះទេ?

រីនៈ	ចា៎!ឆ្ងាយដែរ អាភ្នំលិចទៅចេះ ចំងាយប្រហែល២គីឡូ ។ អាហ្នឹងសាកសពងាប់ដែលគាស់បាន ។

វណ្ណៈ	គាស់ឆ្អឹងយកដាក់នៅភ្នំជញ្ជាំងហ្នឹង តើប្រជាជនយកទៅគោរពវិញ្ញាណខ័ណ្ឌអីដែរ?

រីនៈ	ចា៎! ពេលដែលគេធ្វើបុណ្យអី គេនឹកទៅ ។

វណ្ណៈ	បាទ!ហើយគេដែលធ្វើបុណ្យនៅហ្នឹងទេ?

រីនៈ	គេធ្វើ ។

វណ្ណៈ	ធ្វើបុណ្យដែរ?

រីនៈ ចា៎!

វណ្ណៈ ចុះឆ្អឹងដែលគាស់ដាក់ភ្នំជញ្ជាំងហ្នឹង ច្រើនទេឆ្អឹងហ្នឹង?

រីនៈ ឆ្អឹងហ្នឹងខ្ញុំមិនបានទៅអើតអីផង ដូចវាឃើញខ្មោចហ្នឹងវាឆ្អែត ។

ប្ដី : សម័យហ្នឹងឆ្អឹងច្រើន ប្រហែលជា២-៣បាវនោះ ។

វណ្ណៈ ភ្នំជញ្ជាំងហ្នឹង នៅហ្នឹងមានវត្តដែរ?

រីនៈ ចា៎!មាន ។

វណ្ណៈ អីចឹងបានគេយកទៅដាក់នៅហ្នឹង?

រីនៈ ចា៎!

វណ្ណៈ អីចឹងដល់ពេលបែក៧៩ វៀតណាមចូលហ្នឹង តើប្រជាជនមានកំហឹងឈឺចាប់ ដេញកាប់សម្លាប់ពួកដែលធ្វើបាបយើងហ្នឹងដែរ កាលហ្នឹងដែលមានទេ?

រីនៈ កាលហ្នឹងខ្លះក៏ដេញទៅ ខ្លះក៏អត់ទៅ ហើយដល់ពេលគេរៀបចប់គេអ៊ូអរាក់ហ្នឹង វារត់ទៅចេះវិញ ទៅភ្នំឆត្រវិញ ។

វណ្ណៈ វារត់មុន?

រីនៈ ចា៎!រត់មុន ។

វណ្ណៈ ពួកហ្នឹងវាដឹងដែរ?

រីនៈ ចា៎! វាដឹងដែរ វាមាននៅឲ្យយើងដេញកាប់វាណា វារត់ទៅ ។

វណ្ណៈ រត់ទៅភ្នំឆត្រ?

រីនៈ ចា៎!

វណ្ណៈ អីចឹងមីងអត់ដែលស្គាល់យាយចែម ច្បាស់ទេ?

រីនៈ ចា៎!

វណ្ណៈ គ្រាន់តែគាត់មកកាន់កាប់នៅតំបន់៥ហ្នឹង?

រីនៈ ចា៎!មិនទាន់ឃើញមុខច្បាស់ទេ ។

វណ្ណៈ ហើយពេលដែលសម័យហ្នឹងឃើញមានមនុស្សស្លាប់ច្រើន ហើយប្រជាជនអត់អាហារអីចឹង?

រីនៈ ចា៎! ប្រជាជនអត់អាហារ អត់ទឹក ។

វណ្ណៈ ចុះមិនគួរណានៅស្រុកហ្នឹងខ្វះទឹក ខ្វះអីណ៎?

រីនៈ ឡើងទៅចេះៗត្រូវខាសទឹក ខែចេត្រ សូម្បីតែទឹកអណ្ដូងផងបានក៏វាលំបែកគ្នាដែរ ។

វណ្ណៈ	អីចឹងបើមីងគិតមើល ទំរាំតែលើកទំនប់ហ្នឹងហើយមនុស្សស្លាប់ច្រើនទេ?

រីនៈ	ច្រើន ស្លាប់ច្រើនណាស់ ។

វណ្ណៈ	ប្រហែលរាប់ពាន់នាក់មើលទៅ?

រីនៈ	អ៊ូ!រាប់ពាន់រាប់ម៉ឺននោះ អាណាវ៉ៃចោល អាណាដែលបកមកវិញឈឺស្លាប់ ។ ខ្ញុំហ្នឹងវិសតែស្លាប់នឹងគេដែរហ្នឹង ដូចថាយាយចែម យើងនៅនេះ ដល់យើងទៅរែកទៅចាញ់ស្រុកចាញ់ស្រែមកដល់ឈឺ ហើយខ្ញុំបាក់មកដល់សព្វថ្ងៃអត់ដែលជាទេ ចេញពីហ្នឹងម៉ោឈឺរហូត ។ ហើយខ្ញុំសង្កេតមើល អ្នកដែលរែកយ៉ាប់ម៉ាស្រែករខ្ញុំអត់មានអ្នកណាធាត់មួយណាទេ សុទ្ធតែស្គមទាំងអស់ ដូចវាបាក់កម្លាំង ។

វណ្ណៈ	ដល់ពេលចប់ហើយ ដូចថាប្រជាជនក្នុងភូមិយើងអត់មានរត់ឡើងភ្នំទេ មានឡើងខ្លះដែរឬក៏ម៉េចដែលកាលហ្នឹង?

រីនៈ	រត់ឡើងភ្នំអី?

វណ្ណៈ	រត់ទៅលិចទៅអី ពេលវៀតណាមចូលម៉ោមីងអីមានរត់ទៅគេឯងទេ?

រីនៈ	ទេ អត់មានរត់ទេ ។

វណ្ណៈ	នៅក្នុងភូមិ?

រីនៈ	ចា៎!

វណ្ណៈ	យើងប្រជាជនធម្មតា?

រីនៈ	ចា៎!អត់បានរត់បានអីទេ ។

វណ្ណៈ	ដល់ពេលះអីចឹងទៅ មីងរត់នៅក្នុងភូមិហ្នឹង ៧៩ហ្នឹងនៅក្នុងភូមិឃុំហ្នឹង តើមានសភាពយ៉ាងម៉េចដែរមីង?

រីនៈ	កាលហ្នឹងអត់អីទេ ស្ងាត់ជ្រៀប ។

វណ្ណៈ	ហើយមានខាងខ្មែរក្រហមឡើងអ៊ុកឡុកអីទៀតទេ?

រីនៈ	វាឡើងម៉ោតែយប់ចេះ វាមកយកអ៊ីវ៉ាន់រួចវាឆាប់បកទៅវិញ ឆ្លងថ្នល់ទៅខាងនោះ វាធ្វើបាបតែអ្នកខាងនោះទេ ។

វណ្ណៈ	អីចឹងពេលហ្នឹងវៀតណាមម៉ោក្នុងភូមិក្នុងអីអីចឹងទៅ?

រីនៈ	ចា៎! ដូចថាវាអត់ហ៊ានឆ្លងថ្នល់ជាតិមួយនេះ វាលោតទៅខាងជើងថ្នល់ជាតិ ។

វណ្ណៈ	អីចឹង៧៩ហ្នឹងមីងម៉ោនៅក្នុងភូមិវិញ ហើយមីងរៀបការឆ្នាំណាដែរ?

រីនៈ	ខ្ញុំការឆ្នាំ៨០ ។

វណ្ណៈ ឆ្នាំ៨០?

រីនៈ ចា៎!

វណ្ណៈ មានភ្លើងមានអីអញ្ចឹងទៅ?

រីនៈ មានភ្លើងមេក្រូ។

វណ្ណៈ មានលុយចងដៃកាលហ្នឹង?

រីនៈ ចងដៃអង្ករ ចងដៃលុយខ្លះ កាលហ្នឹងគេដេញឲ្យបើកវគ្គ ប្រពន្ធតាឡែង គាត់ប្រាប់ គាត់ថាស្រុកជិតស្រួលហើយ នារីយុវជនកុំអាលទាន់យកប្ដីថាអីចឹង កុំទាន់បើកវគ្គ ស្រុកយើងបានមេក្រូបានអ្នកបួសអ្នកចំលងវិញហើយ ខ្ញុំនៅតស៊ូដល់បានរបស់ខ្ញុំ។

វណ្ណៈ អ្ហូ!អីចឹងនិយាយពីរឿងរៀបការ នៅក្នុងសម័យហ្នឹងគេមានបង្ខំឲ្យរៀបការទេ?

រីនៈ គ្មានពីណាបង្ខំទេ គ្រាន់តែស្រេចតែចិត្តយើងស្នេហ៍ក្រុខ្លួនយើង។

វណ្ណៈ អត់អីដែរ?

រីនៈ ចា៎!

វណ្ណៈ ប៉ុនធ្វើការជាទំងន់?

រីនៈ ចា៎!

វណ្ណៈ អីចឹងមីងរស់មកដល់សព្វថ្ងៃនេះ តើនៅស្រុកភូមិនេះ តើប្រជាជនប្រកបមុខរបរធ្វើអីដែរមីង?

រីនៈ ប្រជាជនធ្វើតែស្រែយើងហ្នឹងឯង។

វណ្ណៈ ធ្វើស្រែចំការអីចឹង?

រីនៈ ចា៎! ធ្វើស្រែធ្វើចំការទៅ។

វណ្ណៈ ចុះមីងគិតថាសម័យខ្មែរក្រហមដូចថា ដែលធ្លាប់ធ្វើបាបប្រជាជនអីអីចឹង ហើយមកដល់ឥឡូវមានតុលាការកាត់ទោសអីចឹង តើមីងយល់ថា មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងជាការត្រឹមត្រូវដែរឬអត់?

រីនៈ ហ៊ើយ!បានទុកជាការត្រឹមត្រូវអីទេ ព្រោះតែវាកាចសាហាវចេះ មិនសមជារាប់ជានេះទេរាប់ជាសត្វនិរច្ឆានទៅវិញ។

វណ្ណៈ អីចឹងមីងថាមានតុលាការកាត់ទោសទាំងអស់ហ្នឹង គឺជាការត្រឹមត្រូវហើយមីង?

រីនៈ ចា៎!

វណ្ណៈ បាទ!ហើយសព្វថ្ងៃមីងដឹងថាពីណាខ្លះ កំពុងជាប់ឃុំនៅតុលាការទេ?

រីនៈ មានលោកអីទេ សព្វថ្ងៃនិយាយមិនចាំទេ ។

វណ្ណៈ រាល់ថ្ងៃនេះ ឌុច ប្រធានគុកទួលស្លែង គាត់ត្រូវបានកាត់ទោសហើយ ប៉ុន្តែនៅប្រហែលជាមិនដល់១ខែទៀតទេ ប្រកាសថាគាត់ត្រូវជាប់គុកប៉ុន្មានៗឆ្នាំម្តងទៀត ។ ព្រោះលើកមុនគេកាត់ទោសគាត់ថា ឲ្យគាត់ជាប់គុក៣៥ឆ្នាំ ក្រោយមកទូទាត់ហើយនៅសល់ជាង១០ឆ្នាំ ហើយគាត់អត់សុខចិត្តទេ គាត់ទៅប្តឹងខទូរណ៍សុំឲ្យគាត់រួចខ្លួន ប៉ុន្តែគេបានជំនុំជំរះហើយ ប៉ុន្តែនៅចេញសាលក្រមម្តងទៀត នឹងបិទសាលក្រមជាស្ថាពរតែម្តង ។ តែម្តងទៀតលែងតវ៉ាបាន ហើយតែប៉ុន្មានប៉ុណ្ណឹង?

រីនៈ ចា៎!

វណ្ណៈ ហើយនៅក្នុងឆ្នាំនេះដដែល គេត្រូវកាត់មេដឹកនាំធំៗចំនួន៤រូបទៀតមាន តានួន ជា តាខៀវ សំផន តាអៀង សារី ប្រពន្ធអៀង សារី សព្វថ្ងៃហ្នឹងពួកគាត់មានវ័យចំនាស់ហើយ ដូច៨០ជាង ៧០ជាងហើយ ប៉ុន្តែនៅក្នុងតុលាការហ្នឹងគេបានឃុំខ្លួនគាត់ ហើយគេកាត់ ទោសគាត់នៅក្នុងឆ្នាំនេះដែរ ។ អ៊ីចឹងមីងគិតថាកាត់ទោសរកយុត្តិធម៌ឲ្យប្រជាជនដែលបាន ស្លាប់ទៅហ្នឹងជាការត្រឹមត្រូវឬក៏យ៉ាងម៉េច?

រីនៈ កាត់ហ្នឹងត្រឹមត្រូវហើយ ។

វណ្ណៈ បាទៗ! អ៊ីចឹងខ្ញុំអរគុណមីងច្រើនហើយមីង ។

រីនៈ ចា៎ៗ!

«ចប់»